Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 1/2 (October 2000): 68–79

# "Faith" in the Book of Ruth

Russell H. BOWERS, Jr.

## Background

The refreshing story of Ruth takes place "in the days when the judges ruled" (Ruth 1:1). This was in general a morally and religiously abysmal era, when "Israel had no king" and "everyone did as he saw fit" (Jud 21:25; cp 17:6; 18:1; 19:1). With no central government to encourage stability, Israel cyclically invoked God's help against her enemies but quickly fell away once it was received (Jud 2:10–19; 10:6–16). The nation's neighbors exploited her weakness by invading and oppressing her citizens.

Against such a background, Ruth's protagonists demonstrate that even in the darkest times people may be found who love God and live righteously. On the one hand, Micah's idolatry and opportunism (Jud 17), Dan's rapacity (Jud 18), Gibeah's debauchery, Benjamin's preference for tribe over justice, and Israel's rash vows and antidotes (Jud 19–21), depict the general tenor of the times. By contrast, the decisive faith of Ruth and the generous character of Boaz blaze as novae in the midnight sky. Further, we see God's grace in mellowing the embittered Naomi and in keeping his word to provide a ruler (and later messiah) through Judah.

The Talmud teaches that Samuel wrote the book of Ruth, though not all modern scholars concur. It falls in the third part of the Hebrew canon, the *kethubim* or "writings" (parts one and two

being the *torah* or "law" and the *nebi'im* or "prophets."[1] In the Talmud Ruth was the first book in the *kethubim*, but was later transferred to the *megilloth*, a collection of five rolls within the *kethubim*. Each of the *megilloth* is read during one of the Jewish feasts; Ruth, the second, is read during the Feast of Weeks or Pentecost at the end of the grain harvest.[2] Later, the Septuagint or Greek translation of the Old Testament, followed by the Latin Vulgate and subsequent Western translations, placed Ruth after Judges because of their close relation in time.




[1]See Luke 24:44 where Jesus spoke about "the Law (*torah*) of Moses, the Prophets (*nebi'im*), and the Psalms (which is often the first and certainly the longest book of the *kethubim*)."

[2]The other books of the *megilloth* are Song of Songs (which is read at Passover), Lamentations (read on the ninth of Ab), Ecclesiastes (read during the Feast of Booths), and Esther (read during Purim).

## A Homiletic Approach

This article will not attempt to exegete the book, but rather suggest one homiletic approach and then propose further themes for study. It is possible to trace the development of Ruth's *faith* through the book as follows: the *decision* of faith (1), the *work* of faith (2), the *request* of faith (3), and the *reward* of faith (4).

**The Decision of Faith (chapter one)**

Chapter one begins with Elimelech and his family moving to Moab to escape a famine. The text does not state whether he inquired of God before leaving Judah, or instead made this decision on his own. However this may be, his actions recall those of Abraham, who earlier had left the land of promise for Egypt because of famine with no recorded authorization by God, and demonstrated a lack of faith while there (Gen 12:10–20). It is possible (but not certain) that Elimelech's lack of faith in God to provide in Judah stands by design in the story in contrast with Ruth's decision to abandon Moab for Judah, and its gods for Yahweh. At any rate Elimelech, whose name means "my God is king," leaves Bethlehem, the "house of bread," because of a famine. His purpose was to "sojourn" or "live for a while" (גּוּר) there. But then as now such "temporary" departures often have a way of becoming more permanent than intended. Elimelech himself died, his sons married, and after ten years they too perished. The "sojourn" out of the land of promise had taken on the appearance of a settled change of address.

In time the widowed[3] Naomi hears that Yahweh has "come to the aid of" his people and lifted the famine. So she and her two daughters-in-law start out for Judah. Before they have gone far Naomi counsels them to return home, praying that they find "rest" in the home of another Moabite husband since they could not wait

---

[3]The repeated note that Naomi "was left with her two sons (v. 3)" and that she "was left without her two sons and her husband (v. 5)" underscores her loss and desolation.

for sons from her even if (as seemed unlikely) she were to bear them. Naomi (נָעֳמִי), a name which means "pleasant," laments that her life has become "bitter," and adopts that name (מָרָא, "Mara") for herself (1:20). Not only has the "pleasant" woman become "bitter," but the "full" is now "empty" (1:21). The fullness the family had hoped to gain by leaving Judah had not materialized. Her life has become bitter and empty because in her view Yahweh's hand had gone out against her. God never rebukes her for that assessment, but by the story's end has so worked that she has a "son" (4:17) who will "renew [her] life and sustain [her] in [her] old age" (4:15). Thus the bitter one will once again enjoy pleasantness; the empty will again be full. But, not imagining that such a happy outcome could await her, Naomi urges her daughters-in-law to return to Moab to seek "rest" while she goes home to Judah to pursue her lot alone.

At first both assure Naomi they would go with her. But after Naomi outlines her own plight and their prospects, Orpah returns to Moab. By contrast, in her classic reply Ruth binds herself to her mother-in-law. She commits herself firmly to share her lot. As part of that commitment, Ruth declares that Naomi's God will be her God (1:16) and takes an oath in Yahweh's name (1:17), so that Boaz later correctly observes that the Moabitess has come to take refuge under the wings of Yahweh, the God of Israel (2:12). This is Ruth's *decision of faith.*

This decision is worth examining. First, it was made in the face of the negative prospects it entailed. Humanly speaking her future looked better if she were to follow Orpah back to Moab—a husband, a home, and "rest" more likely awaited her there. A biblical decision of faith often means abandoning what appear to be good earthly prospects for seemingly poorer ones.[4] Second, the

---

[4]This motif runs throughout the scriptures. Notable examples include Abraham's willingness to take the arid regions of Canaan in contrast with Lot's choice (Gen 13), and Jesus' instruction that the one who seeks to save his life will lose it, while the one who loses his life for the sake of Jesus and the gospel will find it (Matt 16:25–26 and parallels).

decision was made firmly. One reason God honored her faith, and her story is told today, is that the choice she made was clear and decisive. Throughout the scriptures, that is the kind of faith God wants.[5] Third, Ruth's decision determined her destiny. Orpah chose one way, apparently based on her human vision and analysis—what may be called "walking by sight, not by faith" (in contrast with 2 Cor 5:7)—and we hear no more of her. Ruth made a contrary choice, and all the good that she soon came to enjoy followed as a consequence. Despite the bleak prospects, Ruth chose decisively to accompany Naomi and trust Yahweh, and that decision set in motion the events which produced all the good she soon enjoyed.

**The Work of Faith (chapter two)**

But does faith stop with a decision, or even a verbalization of that decision? Does a decision to trust God mean that the new believer sits and waits for God to act on his or her behalf? Do we "claim" a blessing and wait for God to supernaturally bestow it upon us? Is faith divorced from works?

Not so with Ruth. She acted on her word, accompanying Naomi to Bethlehem in Judah as the barley harvest was beginning (1:22). Barley, often considered inferior to wheat,[6] was harvested in April–May; wheat followed a few weeks later. Rather than wait for her and her mother-in-law's needs to be miraculously supplied, Ruth proposes that she glean in the barley fields. As standing grain was cut and bound into sheaves, some would inevitably be missed or dropped. The Mosaic Law prescribed that these should be left

---

[5]See, for example, Joshua's challenge to decisively choose which god they would follow (Josh 24:14–15), Elijah's call for decision in the question of Yahweh vs. Baal (1 Ki 18:21), and the glorified Lord's revulsion against lukewarmness (Rev 3:15–16).

[6]For example, wheat was twice as expensive as barley in 2 Ki 7:1; three times as expensive in Rev 6:6. The comparison of Gideon and Israel to "a round loaf of barley bread" in Jud 7:13 aptly symbolizes their inferiority to Midian.

"for the poor and the alien."[7] This good law simultaneously provided for the poor and encouraged their dignity by allowing them to *work* for their food rather than simply *beg* for it. Thus the twin evils of tight-fistedness on the part of the wealthy and a sense of entitlement to unearned welfare on the part of the poor were avoided. Gleaning was hard work, it was humble work, it did not generally yield an abundant return, but it did provide something. Ruth was humble and committed enough to be willing to undertake the task of seeking permission (2:2, 7), of gleaning, and of gleaning *barley*. In doing so she displayed not a *lack* of faith that her new God would provide, but rather a *living* faith[8] which was willing to pursue the means that this God had already ordained to supply her needs. Not only does she work, but she works long and hard.[9]

Unbeknown to Ruth, she happened to choose a field belonging to Boaz, a respected relative of Elimelech (2:1, 3, 20). The greetings exchanged between him and his harvesters (2:4) suggest his godly, kindly character. Even in the dark days of the judges God has those who fear and honor him. He will later be seen to be a generous (2:14–16; 3:15), honest (3:18), prudent and hardworking man (4:1–10). He notices and inquires about Ruth, and provides generously for her once he learns who she is. He does this because he has been told about her *work of faith*—how she has *taken refuge* under Yahweh's wings and *worked hard* for her mother-in-law (2:11–12). He prays that God would bless her (2:12)—little knowing that he will be the means through whom that blessing will come. He urges Ruth for her safety to stay with his fields and workers (2:8–9)—a matter with which Naomi

---

[7]Lev 19:9–10; 23:22; Deut 24:19–22. Boaz went beyond what the Law required (2:15–16; 3:15). The result was that Ruth came home with an extraordinarily large quantity for a gleaner—about 22 liters (2:17). Thus in one day's work she gathered enough food to feed the two women for three weeks or so. This surprising amount prompted Naomi's question of Ruth and blessing on the as yet unknown landowner (2:18–19).

[8]See James 2:14–26.

[9]2:7, 17–18, 23. The two harvest seasons mentioned in 2:23 would have lasted about seven weeks.

concurs (2:22)—again suggesting the general darkness of the times.

**The Request of Faith (chapter three)**

Faith may be strong to make a decision which apparently contravenes common sense and then to act decisively on that decision. But biblical faith is not content with what it alone can achieve. It acknowledges its need, and asks God to do what it cannot.

Earlier Naomi had prayed that Yahweh would grant her daughters-in-law "rest" (מְנוּחָה) in the home of another husband (1:9). It had seemed highly unlikely to her that Ruth—a foreigner[10]—would ever be so blessed in Judah. But now, with her own needs being met and hopes renewed, Naomi turns her thoughts away from her bitter bereavement to her daughter-in-law, and suggests that she will now try to find "rest" (מָנוֹחַ, translated in the NIV as "a home")[11] for her (3:1). The one through whom she will seek it is Boaz, who has already shown himself to be kindly disposed toward Ruth.

The Torah provided that if brothers were living together and one died without a son, the surviving brother should marry the widow. The first child born to that union would bear the deceased's name (Deut 25:5–10). It was this practice which lay behind the Sadducees' question of Jesus in Matt 22:23–33 and parallels. By outlining the plan of 3:3–4, Naomi is urging Ruth to tacitly ask Boaz to perform this responsibility of levirate marriage. Spreading the corner of one's garment over another (3:9) is a request for marriage, as Ezek 16:8 suggests.

---

[10]Repeated references to Ruth as "the Moabitess" throughout the book (1:22; 2:2, 6, 21; 4:5, 10) emphasize her foreignness.

[11]The root of both מְנוּחָה and מָנוֹחַ is נוּחַ, which "signifies not only absence of movement but being settled in a particular place (whether concrete or abstract) with overtones of finality, or (when speaking abstractly) of victory, salvation, etc." מָנוֹחַ "denotes a place of *nûaḥ* (motionless, security) for animals or people, i.e. a place to settle down, a home" [*TWOT*, s.v. נוּחַ]. The word here thus implies security, not leisure.

This may strike the reader as rather forward, but faith is willing to humble oneself and ask for big things. The persistence of the Syrophoenician woman (Matt 15:21–28; Mark 7:24–30) further illustrates that truth. Here Ruth, who through her *work of faith* has been supplying the needs of both herself and Naomi, makes a bold, tacit *request of faith* that more be done for her.

A "threshing floor" was an elevated level place of smooth rock or pounded earth, usually east or downwind from the city. Workers tossed the threshed grain into the breeze that usually rose in the afternoon from the Mediterranean. The chaff would blow away, but the heavier grain fall to the ground to be gathered. Here the unpretentious Boaz would spend the night, whether to guard his harvest or in celebration of it. Although some interpreters see lewdness in Ruth's action of "uncovering Boaz' feet," both Boaz' statement in 3:11 that Ruth is known as a woman of character, as well as the whole tenor of the story, argue against that assessment. She is simply—but admittedly quite clearly—asking that Boaz perform his obligation as kinsman-redeemer (גֹּאֵל). Her bathing, perfuming, and dressing (3:3), of course, were not designed to discourage his response to her.

Whether or not Ruth knew it, Elimelech had a relative closer than Boaz who retained the first right to buy his estate and take Ruth as his wife. Boaz, startled in the middle of the night as he sleeps on the threshing floor, awakes to find—of all things!—a woman at his feet. Learning her identity and hearing her request, Boaz proposes to Ruth that in the morning he will inform this relative of his option to redeem and then, if this closer kinsman declines, promises to do it himself. He then has Ruth lie down until morning, and before she leaves gives her six measures of barley.

Naomi naturally is eager to hear how things went. When she hears Ruth's story and sees the grain Boaz has sent, she urges Ruth to *wait* to see the outcome, assured that Boaz would act on his promise that very day.

And so the *request of faith* becomes the *rest of faith.* Faith takes courage to *ask* for big things—even that mountains be

removed (Matt 21:21–22)—and then *rests* in faith that God will act. One is reminded of Jehoshaphat, who *interceded* with God against the coalition marching against him, and who was told to *rest and wait* for God's deliverance (2 Chron 20). Hannah pled for a son and then, resting in faith for God's answer, "went away and ate something, and her face was no longer downcast" (1 Sam 1:18). These and others made *requests of faith* to God—not for extravagant items for self-indulgence, but for basic needs in line with his covenant—and then *rested* in anticipation of the answer. Again it is helpful to remember that Ruth's request followed both her *decision of faith* and her *work of faith*, and did not comprise a lazy or escapist approach to life's needs and responsibilities. Her request was made for what God had already promised in the Law but which was beyond her ability in herself to make happen.

**The Reward of Faith (chapter four)**

Chapter four finds Boaz hard at work fulfilling his promise. He will do everything with energy, propriety, and thoroughness.

The "town gate" (4:1) was a public center where business was often transacted and judgments rendered.[12] Boaz went to the gate and, when the closer relative approached, had him turn aside to this "courtroom." He then invited a full quorum of ten elders to witness his discussion. Upon hearing Boaz' word that Elimelech's property is for sale, the kinsman expresses interest in acquiring it. But when he learns that that entails marrying Ruth and raising an heir for Elimelech, he demurs. Then follows a description of a practice which had become archaic and required explanation by the time the book was written—that of giving a sandal to legalize a transaction (4:7–8). Boaz then states his intentions to redeem the property and marry Ruth as clearly and firmly as did Ruth to

---

[12]See, e.g., Gen 23:10, 18; 34:20, 24; Deut 17:5; 21:19; 22:15, 24; 25:7; and throughout the O.T.

abandon Moab and follow Naomi (4:9–10, cp. 1:16–17).[13] The ten elders affirm that they have witnessed the transaction, implying that all is in order. They invoke Yahweh's blessing on this proposed marriage, praying that God would bless it with children. In time Yahweh answered their prayer. He enabled Ruth to conceive (4:13) and bear a son.

And now Naomi's fortunes have turned full cycle. She left Judah full, returned empty (1:21), and now has been filled again. The woman named "Pleasant" who assumed the title "Bitter" now has the "pleasant" prospect of a גֹּאֵל who will renew her life and sustain her in her old age (4:15).[14] She takes the child in her lap and cares for him (4:16). All this because the blessing of Yahweh has come to her through her return to the land of promise, and the ministry of her faithful daughter-in-law who was better to her than seven sons (4:15).[15]

The genealogy that follows demonstrates just how significant and far-reaching Ruth's *decision, work,* and *request* of faith proved to be. Perez, with whom the genealogy starts (4:18), was a son of Judah,[16] to whom rulership was promised by Jacob.[17] Sure enough, Obed—the child born to Boaz and Ruth—becomes the father of Jesse, who himself was the father of David—king of Israel and human ancestor of Jesus the Messiah.[18] Who ever knows

---

[13]Just as Boaz' selfless, faithful character parallels that of Ruth, so the unwilling kinsman-redeemer's more self-centered and "pragmatic" character parallels that of Orpah.

[14]Previously in the book Boaz had been considered the גֹּאֵל. But now in 4:14–15 that title is applied to the child born to Boaz and Ruth as well. Obed (עוֹבֵד) will serve (עָבַד) to "redeem" Naomi from emptiness, insignificance, and insecurity.

[15]This is very high praise in a day when sons often seemed to be valued more than daughters.

[16]Gen 38 tells the story of Perez' conception and birth. Cp. Gen 46:12.

[17]Gen 49:10.

[18]Having Ruth the Moabitess in his ancestry may help explain why, though Moab was included among Israel's enemies (1 Sam 12:9;

how significant will be one person's *decision, work,* and *request* of faith? Who ever can tell how great the *reward of faith* for any one person will be? Not only was Ruth blessed with "rest" in the home of a husband and child, but she enjoyed the respect of those who knew her (3:11; 4:15), and became an ancestor of the messiah. All this for a foreigner who put faith in the God of Israel and acted on that faith.[19]

## Other Considerations

As stated at the beginning, this article does not attempt to exegete the book of Ruth, but simply to suggest one line of thought—the character and development of Ruth's faith—that runs throughout it. Other themes which may be profitably pursued include:

- a character study of Naomi who, though living in a foreign land for a decade or more and at the end of that time berating the lot assigned to her by Yahweh, nevertheless was so compelling a personality that Ruth would abandon her home, her prospects, and her gods to follow her to Judah.
- reflections on the sovereignty of God, who works behind the scenes so that Ruth "happens" to choose Boaz' field in which to glean, causes Boaz to awaken at this right time, ensures that the close relative passes the gate the next

---

14:47), David took his parents to the king of Moab for safekeeping during the time he fled from Saul (1 Sam 22:3–4).

[19]The genealogy of Jesus in Matt 1 lists four women, none of whom would ordinarily be expected to have been granted such an honor. Tamar had been Judah's daughter-in-law, and his liaison with her was immoral (Gen 38). Rahab was a foreigner from the doomed city of Jericho, and by many translations a prostitute. Ruth was a foreigner and a Moabitess—a fact reiterated throughout the book (see footnote 10). Deut 23:3 states that ordinarily no Moabite could enter the assembly of Yahweh even down to the tenth generation. Finally, Bathsheba or "Uriah's wife" should not have been David's spouse. God's dealings with Israel—and with humanity as a whole—are a matter of grace.

morning, enables Ruth to bear a son, etc. Similarities may be drawn to the book of Esther, where God's name is not mentioned but his work in the events of the story is very clear.

- a study of "harsh" prayers to or statements against Yahweh in the Bible on the part of his believers, including Naomi, Job, Asaph, Jeremiah, etc.
- a study of the גֹּאֵל or kinsman redeemer, who 1) must be a close relative, 2) must be able to redeem, and 3) must be willing to redeem. Parallels can be drawn to Jesus, the great antitype of the Old Testament גֹּאֵל, who 1) took on humanity that he might be our "close relative" (Heb 2:14–18; 4:14–16), 2) is able to redeem (Heb 7:25), and 3) was willing to redeem (John 10:17–18; Luke 22:41–42). The word גָּאַל, of which גֹּאֵל is a participle, occurs 23 times in Ruth.[20]
- the contribution of the book of Ruth to the concept of covenant-loyalty or loyal-love (חֶסֶד, 1:8; 2:20; 3:10).
- the role that Ruth's submission to her mother-in-law and willingness to obey her played in the good that came to her.

May God grant that as we study the faith and character of Ruth all of us—men and women—would appropriately follow in her steps.

---

[20]2:20; 3:9; 3:12 (2 times), 13 (4 times); 4:1, 3, 4 (5 times), 6 (5 times), 7, 8, 14.

សំណុំឪកឃ្មុំ ១/២ (តុលា ២០០០) ៨០-៩៦

# “ជំនឿ” នៅក្នុងកណ្ឌគម្ពីរនាងរស់

ដោយ លោក រ៉ស់ បាទទើស

✱✱✱✱✱✱✱✱✱✱✱✱✱✱

## ប្រវត្តិដើម

រឿងនាងរស់នេះកើតឡើងស្រស់ៗនៅក្នុង “សម័យដែលពួកចៅហ្វាយគ្រប់គ្រង” (នាងរស់ ១:១) ។ រឿងនេះរៀបរាប់ជាទូទៅពីភាពអាក្រក់ជួរជាតិផ្នែកសីលធម៌ និងផ្នែកសាសនាក្នុងសម័យកាលមួយដែល “ប្រទេសអ៊ីស្រាអែលគ្មានស្តេចគ្រប់គ្រង” ហើយនិង មនុស្សគ្រប់រូបធ្វើអ្វីៗតាមតែក្បាលចិត្តរបស់ខ្លួន” (ចៅហ្វាយ ២១:២៥ ជំពូក ១៧:៦; ១៨:១; ១៩:១) ។ ដោយគ្មានរដ្ឋាភិបាលគ្រប់គ្រងដើម្បីជំរុញឲ្យមានស្ថេរភាព អ៊ីស្រាអែលបានអធិស្ឋានសុំជំនួយពីព្រះជាម្ចាស់ ដើម្បីប្រឆាំងតបតជាមួយនឹងខ្មាំងសត្រូវរបស់ខ្លួនម្តងហើយម្តងទៀតកាលពីសម័យនោះ (ចៅហ្វាយ ២:១០-១៩; ១០:៦-១៦) ។ ប្រទេសជាតិដែលនៅជិតខាង ដោយឃើញថាអ៊ីស្រាអែលខ្សោយដូច្នេះហើយ ទើបគេចូលលុកលុយទន្ទ្រានទី គាបសង្កត់ដល់ប្រជារាស្ត្រអ៊ីស្រាអែល ។

ផ្អែកលើប្រវត្តិដើមនៃរឿងនេះ នាងរស់ជាតួអង្គសំខាន់ ដែលបង្ហាញយ៉ាងច្បាស់ពីជំនឿរបស់ខ្លួន ទោះបីជាស្ថិតនៅក្នុងសម័យដ៏ខ្មៅងងឹតយ៉ាងណាក៏ដោយ ក៏នាងនៅតែស្រឡាញ់ព្រះជាម្ចាស់ និង រស់នៅដោយសុចរិតបំផុត ។ ផ្ទុយទៅវិញលោក មីកា ជាអ្នកថ្វាយបង្គំរូបសំណាក និងជាអ្នកឱកាសនិយម (ឆ្អិនក្បាលស៊ីក្បាលឆ្អិនកន្ទុយស៊ីកន្ទុយ) (ចៅហ្វាយ ១៧) ការវាយឆក់ប្លន់របស់ពួកអំបូរដាន់ (ចៅហ្វាយ ១៨) អំពើអបាយមុខរបស់ពួកគីបៀរ ពួកបេនយ៉ាមីន គិតពីអំបូររបស់ខ្លួន ដោយមិនខ្វល់ពីសេចក្តីយុត្តិធម៌ឡើយ ហើយនិងការឆាប់នឹងបែរ

រកព្រះ និង ឆាប់នឹងភ្លេចព្រះ របស់រាស្ត្រអ៊ីស្រាអែល (ចៅហ្វាយ ១៩-២១) បង្ហាញឆ្លុះបញ្ចាំងពីសភាពការណ៍ជាទូទៅនៃសម័យកាលនោះ ។ តែផ្ទុយទៅវិញ ជំនឿដ៏មុតមាំរបស់ នាងរស់ និង ទឹកចិត្តដ៏សប្បុរសរបស់បូអូស បានចាំងជះពន្លឺចាំងចែង នៅក្នុងលំហអាកាសដ៏ងងឹតនាពេលពាក់កណ្តាលអាធ្រាត ។ លើសពីនោះទៅទៀត យើងបានឃើញព្រះគុណរបស់ព្រះជាម្ចាស់ ដោយបង្វែដួងចិត្តដ៏ជូរចត់របស់នាង ណាអូមី ឲ្យទៅជាដួងចិត្តផ្អែមឆ្ងាញ់ ហើយរក្សាព្រះបន្ទូលសន្យារបស់ព្រះអង្គ ដែលសន្យាថានឹងផ្តល់ឲ្យមានអ្នកដឹកនាំម្នាក់ (និងក្រោយមកជាព្រះមេស្ស៊ី) តាមរយៈអំបូរ យូដា ។




ក្រុមអ្នកគ្រប់គ្រងច្បាប់របស់យូដាបានប្រាប់ឲ្យដឹងថា សាំយូអែល ជាអ្នកសរសេរកណ្ឌគម្ពីរនាងរស់ ទោះបីជាពួកអ្នកប្រាជ្ញនៅពេលសម័យបច្ចុប្បន្នមិនយល់ព្រមទាំងអស់ក៏ដោយ ។ រឿងនេះចែកចេញជាបីផ្នែក តាមសំណោររបស់

ហេព្រើ (ផ្នែកទីមួយ និងផ្នែកទី២ គឺជា "កណ្ឌច្បាប់" និង ជា "កណ្ឌព្យាការី"[១] ។ នៅក្នុងផ្ទៃ រឿងរបស់កណ្ឌនាងរស់ គឺជាសៀវភៅទីមួយ នៅក្នុងសំណេររបស់សាសន៍ហេព្រើ ប៉ុន្តែក្រោយមក ក៏ត្រូវបានគេផ្ទេរមក ជាការប្រមូលផ្ដុំជាប្រាំផ្នែកនៃសំណេររបស់ហេព្រើនោះ ។ សំណេរនិមួយៗនៃសំណេរទាំងប្រាំនោះគឺយកមកអាននៅក្នុងពិធីបុណ្យនៃពួកយូដាកណ្ឌនាងរស់ជាកណ្ឌទី២ ដែលយកមកអាននៅក្នុងពិធីបុណ្យប្រចាំសប្តាហ៍ ឬ ពិធីបុណ្យថ្ងៃទី៥០ នៅខាងចុងនៃរដូវច្រូតកាត់ប្រមូលភោគផល ។ [២] ក្រោយមក ការបកប្រែព្រះគម្ពីរសញ្ញាចាស់ ត្រូវធ្វើតាមការបកប្រែជាភាសាឡាតាំង និងបន្តបន្ទាប់មកក្នុងការបកប្រែរបស់ពួកបស្ចឹមប្រទេស គេបានដាក់គម្ពីរនាងរស់នៅបន្ទាប់ពីកណ្ឌគម្ពីរពួកចៅហ្វាយ ពីព្រោះតែកណ្ឌគម្ពីរមានការទាក់ទងគ្នាយ៉ាងជិតស្និតនៅក្នុងពេលនោះ ។

## របៀបអធិប្បាយ

អត្ថបទនេះនឹងមិនប៉ុនប៉ងពន្យល់ឲ្យស៊ីជម្រៅនូវកណ្ឌគម្ពីរនេះឡើយ ប៉ុន្តែគ្រាន់តែផ្តល់ការណែនាំពីរបៀបអធិប្បាយ និង បន្ទាប់មកផ្តល់នូវផ្ទៃរឿងសំខាន់សំរាប់សិក្សា ។ យើងអាចស្រាវជ្រាវស្តីពីការចំរើនលូតលាស់នៃជំនឿរបស់នាងរស់ នៅក្នុងជំពូកដូចតទៅ៖ ការសម្រេចចិត្តដោយជំនឿ (ជំពូក ១) , កិច្ចការនៃជំនឿ (២) ការស្នើសុំដោយជំនឿ (៣) ហើយនិងរង្វាន់នៃជំនឿ (៤) ។

**ការសម្រេចចិត្តដោយជំនឿ (ជំពូក ១)**

ជំពូក ១ ចាប់ផ្តើមរៀបរាប់ពីការរត់គេចពីគ្រោះអត់ឃ្លានរបស់លោកអេលីម៉ាឡេក ព្រមទាំងគ្រួសាររបស់គាត់ ទៅកាន់ស្រុកម៉ូអាប់ ។ អត្ថបទនេះមិនបាន

---

(១) *សូមមើល លូកា ២៤:៤៤ នៅត្រង់កន្លែងដែលព្រះយេស៊ូនិយាយពី "ក្រិត្យវិន័យ របស់លោកម៉ូសេ (ភាសាហេព្រើហៅថា តូរ៉ា) កណ្ឌគម្ពីរពួកហោរា និង កណ្ឌទំនុកតម្កើង (ដែលជាញយៗជាកណ្ឌគម្ពីរ ទីមួយ និង តាមពិតទៅជាកណ្ឌគម្ពីរដែលវែងជាងបំផុតនៃសំណេររបស់ពួកហេព្រើ)*

(២) *កណ្ឌគម្ពីរនៃសំណេរទាំងប្រាំនោះ គឺជាបទចំរៀង (ដែលគេយកទៅអាននៅថ្ងៃបុណ្យរំលង) បរិទេវ (អាននៅថ្ងៃទី៩ នៃខែ Ab) សាស្តា (អាននៅពិធីបុណ្យ Booths) និង អេសធើ (អាននៅក្នុង ពិធីបុណ្យ Purim) ។*

បញ្ជាក់ប្រាប់ថាតើគាត់បានទូលសួរព្រះជាម្ចាស់ឬក៏អត់ទេ មុនពេលដែលគាត់ចាកចេញពីស្រុកយូដា ឬក៏ប្រហែលជាគាត់ធ្វើការសម្រេចចិត្តដោយខ្លួនឯង ។ ទោះជាយ៉ាងណាក៏ដោយ ការនេះប្រហែលជាគាត់ធ្វើដូចជាអាប្រាហាំ ដែលបានចាកចេញពីទឹកដីសន្យាជាលើកដំបូង ធ្វើដំណើរទៅកាន់ប្រទេសអេស៊ីព្ទ ដោយសារតែគ្រោះអត់ឃ្លាន ដោយគ្មានកំណត់ហេតុណាមួយបង្ហាញពីការយល់ព្រមពីព្រះជាម្ចាស់នោះឡើយ ហើយនិង បង្ហាញឲ្យឃើញថាគាត់ខ្វះជំនឿលើព្រះជាម្ចាស់ នៅពេលដែលគាត់កំពុងស្នាក់នៅក្នុងស្រុកនោះ (លោកុប្បត្តិ ១២:១០-២០) ប្រហែលជាអាច (ប៉ុន្តែមិនច្បាស់) មានន័យថា អេលីម៉ាឡេកខ្វះជំនឿនៅក្នុងព្រះជាម្ចាស់ ក្នុងការដែល ព្រះអង្គផ្គត់ផ្គង់អាហារឲ្យនៅក្នុងស្រុកយូដា តែផ្ទុយទៅវិញក្នុងសាច់រឿងនេះ នាងរស់នៅតែស្មោះត្រង់ សម្រេចចិត្តចាកចេញពីស្រុកម៉ូអាប់មកកាន់ស្រុកយូដាវិញ ហើយនិង បែរចេញពីព្រះរបស់ខ្លួនមកជឿលើព្រះយេហូវ៉ា(ព្រះយ៉ាវេ) ។ ទោះបីជាយ៉ាងណាក៏ដោយ អេលីម៉ាឡេក ដែលឈ្មោះនោះមានន័យថា "ព្រះជាម្ចាស់របស់ខ្ញុំជាស្តេច" ចាកចេញពីបេថ្លេហឹមដែលមានន័យ "ដំណាក់នៃនំបុ័ង" ដោយសារតែគ្រោះអត់ឃ្លាន ។ គោលបំណងរបស់គាត់ គឺគ្រាន់តែ "ស្នាក់នៅ" ឬ "រស់នៅមួយរយៈ" នៅទីនោះ ។ ប៉ុន្តែបន្ទាប់មកគឺថាឥឡូវនេះការដែលថាចាកចេញទៅ"បណ្តោះអាសន្ន"នោះ តាមពិតទៅប្រែក្លាយទៅជាស្នាក់នៅរហូតទៅវិញ ។ អេលីម៉ាឡេកខ្លួនឯងផ្ទាល់គាត់ក៏ត្រូវស្លាប់ កូនប្រុសរបស់គាត់ទាំងពីរដែលរៀបការរួចបាន១០ឆ្នាំក៏ស្លាប់ដែរ ។ ការ"ស្នាក់នៅមួយរយៈ ក្រៅពីទឹកដីសន្យា គឺបង្ហាញឲ្យឃើញថា បានផ្លាស់ប្តូរអស័យដ្ឋាននៃការតាំងទីលំនៅ ។

នៅក្នុងកំឡុងពេលនៃស្ថានភាពជាស្រីមេម៉ាយ(៣) ណាអូមីឮថាព្រះយ៉ាវេយាងមកដើម្បីជួយរាស្ត្ររបស់ព្រះអង្គឲ្យរួចពីគ្រោះទុរភិក្ស ។ ដូច្នេះគាត់ និង កូនប្រសារស្រីរបស់គាត់ចាប់ផ្តើមធ្វើដំណើរត្រឡប់ទៅស្រុកយូដា ។ មុនពេលដែល

---

*(៣) កំណត់សំគាល់លើកឡើងម្តងហើយម្តងទៀតពី ណាអូមី "នាងត្រូវប្តីស្លាប់ចោល នៅជាមួយកូនប្រុសពីរនាក់ (ខ ៣) ហើយបន្ទាប់មក នាងត្រូវ "ប្តី និង កូនប្រុសទាំងពីរស្លាប់ចោលទៀត (ខ ៥)" បញ្ជាក់សំខាន់លើការដែលគាត់មានការបាត់បង់ និង ការកំសត់ទុរគត៌របស់គាត់ ។*

ពួកគេធ្វើដំណើរមិនទាន់ឆ្ងាយប៉ុន្មាន ណាអូមីបានផ្តល់ការប្រឹក្សាដល់កូនប្រសារស្រីទាំងពីរនាក់ ឲ្យគេត្រឡប់ទៅផ្ទះវិញ ដោយអធិស្ឋានសុំឲ្យគេបាន "សំរាក" នៅក្នុងស្រុកដោយរៀបការប្តីថ្មីទៀត ដែលជាជនជាតិម៉ូអាប់ដូចគ្នា ដោយហេតុថា ពួកគេមិនអាចរង់ចាំរៀបការជាមួយកូនប្រុសរបស់គាត់ (វាហាក់ដូចជាមិនអាចទៅរួចឡើយ ថាគាត់នឹងអាចបង្កើតកូនប្រុស សំរាប់ឲ្យកូនប្រសាររបស់គាត់ធ្វើជាប្តីទៀត) ។ ឈ្មោះណាអូមី មានន័យថា "រីករាយ" ដោយសារតែសេចក្តីទុក្ខសោកដែលជីវិតរបស់គាត់មាននោះ ក្លាយទៅជា "ជូរចត់" ហើយគាត់បានដូរឈ្មោះ ទៅជា (ម៉ារ៉ា) វិញ (១:២០) ។ មិនគ្រាន់តែក្លាយពីស្ត្រី "រីករាយ" ទៅជា "ជូរចត់" ប៉ុណ្ណោះទេ តែថែមទាំងក្លាយពី "ពេញ" ទៅជា "ទទេ" ទៅវិញ (១:២១) ។ ភាពពេញលេញរបស់គ្រួសារ ដែលសង្ឃឹមថានឹងបានទទួលដោយការចាកចេញពីស្រុកយូដានោះមិនចេញជារូបរាងឡើយ។ ជីវិតរបស់គាត់(ណាអូមី)បានក្លាយទៅជាជូរល្វីង និងបាត់បង់គ្មានសល់ ពីព្រោះតាមគំនិតរបស់គាត់បានគិតថា ព្រះយ៉ាវេ (យេហូវ៉ា)បានលូកព្រះហស្តមកទាស់នឹងគាត់ ។ ព្រះជាម្ចាស់មិនបន្ទោសដល់ គាត់ចំពោះការប៉ាន់ស្មានរបស់គាត់ឡើយ ។ ប៉ុន្តែចុងបញ្ចប់របស់សាច់រឿងពិតជាបានសម្រេចមែន ដែលថាគាត់ពិតជាអាចមាន "កូនប្រុស" មួយមែន (៤:១៧) ដែលនឹងផ្តល់នូវ "ការកែប្រែ ជាថ្មីដល់ជីវិតគាត់ និង ជួយផ្តល់ការគាំទ្រដល់ជីវិតរបស់គាត់ នៅក្នុងកាលដែលគាត់ចាស់ហើយនោះ (៤: ១៥) ហេតុដូច្នេះ អ្នកដែលធ្លាប់ឈឺចុកចាប់នោះ បានក្លាយទៅជាមានអំណររីករាយឡើងវិញ អ្នកដែលគ្មានអ្វីសោះ នឹងទៅជាមានពេញពោរឡើងវិញ ។ ប៉ុន្តែ ដោយគាត់មិនដែលគិតស្រមើស្រមៃថា នឹងមានការសប្បាយរីករាយបែបហ្នឹងអាចកើតមានឡើងសោះ ទើបណាអូមីជំរុញ ឲ្យកូនប្រសារស្រីរបស់ គាត់ឲ្យវិលត្រឡប់ទៅម៉ូអាប់វិញ ដើម្បីទៅរកការ "សំរាក" នៅខណៈដែលគាត់ វិលត្រឡប់ទៅស្រុកកំណើត នៅឯយូដាវិញ ដើម្បីទៅរស់នៅកំសត់ម្នាក់ឯង ។

មុនដំបូងកូនប្រសារទាំងពីរនាក់ធានាអះអាងជាមួយ ណាអូមី ថា ពួកគេនឹងទៅជាមួយនឹងគាត់ ។ ប៉ុន្តែបន្ទាប់ពី ណាអូមី រៀបរាប់ពីបញ្ហារបស់គាត់ផ្ទាល់ប្រាប់ដល់គេ និង បញ្ជាក់ប្រាប់ពីហេតុផលរបស់គេចំពោះការដែលគេព្រមទៅតាមគាត់នោះ នាងអ័រប៉ា ក៏ត្រឡប់ទៅឯស្រុកម៉ូអាប់វិញ ។ តែផ្ទុយទៅវិញនាងរស់ឆ្លើយតបទៅម្តាយក្មេកវិញថា នាងស្ម័គ្រចិត្តទៅតាមម្តាយក្មេក ។ នាងប្តូរផ្តាច់

យ៉ាងមុតមាំថា នឹងទៅជាមួយម្ដាយក្មេក ។ ក្រៅពីការប្ដូរផ្ដាច់បែបនេះ នាងរស់ប្រកាសថាព្រះរបស់ណាអូមី ក៏ជាព្រះរបស់នាងដែរ (១:១៦) ហើយបានស្បថដោយនូវព្រះនាមរបស់យ៉ាវេ (១:១៧) ដូច្នេះក្រោយមកបូអូសបានសង្កេតឃើញយ៉ាងច្បាស់ថា សាសន៍ម៉ូអាប់បានមកពឹងជ្រក នៅក្រោមចំអែងស្លាបរបស់ព្រះយ៉ាវេ ជាព្រះរបស់អ៊ីស្រាអែល (២:១២) ។ នេះជាការសម្រេចចិត្ត នៃជំនឿរបស់នាងរស់ ។

សេចក្ដីសម្រេចចិត្ត គឺមានតម្លៃណាស់ក្នុងការធ្វើការសង្កេត ដោយពិនិត្យពិច័យ ។ ទីមួយរឿងនេះផ្ដល់ឲ្យមានហេតុការណ៍ជាអវិជ្ជមាន ។ និយាយតាមនិស្ស័យមនុស្ស អនាគតរបស់នាងរស់មើលទៅហាក់ដូចជាមានភាពប្រសើរឡើង បើនាងព្រមត្រឡប់ទៅម៉ូអាប់ជាមួយនាងអ័រប៉ាវិញ គឺថាអាចមានប្ដីមានផ្ទះ និងបាន "សំរាក" ដែលហាក់បីដូចជាកំពង់រង់ចាំទទួលនាងនៅទីនោះ ។ ការសម្រេចចិត្តនៃជំនឿស្របតាមព្រះគម្ពីរជារឿយៗមានន័យថាត្រូវលះបង់ចោលនូវការល្អប្រសើរតាមគំនិតរបស់លោកិយ ដែលមើលទៅមិនល្អនោះដើរតាមការសម្រេចចិត្តស្របតាមព្រះគម្ពីរ[៤] ។ ទី២ ការសម្រេចចិត្តនោះបានធ្វើឡើងដោយមុតមាំ ។ ហេតុផលទី១ ព្រះជាម្ចាស់ផ្ដល់កិត្តិយសដល់ជំនឿរបស់នាង ហើយនិងរឿងរបស់នាងត្រូវបានគេយកមកនិយាយនៅដល់សព្វថ្ងៃនេះ គឺថាការជ្រើសរើសរបស់នាងគឺច្បាស់លាស់នឹងសម្រេចចិត្តយ៉ាងមុតមាំ ។ នៅក្នុងបទគម្ពីរទាំងមូល គឺជំនឿបែបនេះហើយ ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ[៥] ។ ទីបី ការសម្រេចចិត្តរបស់នាងរស់ កំណត់ឲ្យឃើញពីទិសដៅអនាគតរបស់នាង ។ នាង

---

[៤] *គំនិតនេះបានលេចឡើងនៅក្នុងគម្ពីរទាំងមូល ។ គំរូគួរឲ្យកត់សំគាល់ រាប់បញ្ចូលទាំងការស្ម័គ្រចិត្តរបស់អាប្រាហាំ ដោយយល់ព្រមយកតំបន់មិនសូវមានជីជាតិ នៃទឹកដីកាណាន ដែលផ្ទុយពីការជ្រើសរើសរបស់ ឡុត (លោកុប្បត្តិ ១៣) ហើយនិងសេចក្ដីបង្រៀនរបស់ព្រះយេស៊ូ ដែលបានបញ្ជាក់ថា អ្នកណាដែលចង់បានជីវិតនោះ នឹងបាត់ជីវិត តែអ្នកណា ដែលបាត់ជីវិត ដោយព្រោះព្រះយេស៊ូ និងដំណឹងល្អ នឹងបានជីវិតវិញ (ម៉ាថាយ ១៦:២៥-២៦) ។*

[៥] *សូមមើលគំរូនៃការជ្រើសរើសរបស់ យ៉ូស្វេ ដោយមុតមាំក្នុងការជ្រើសយកព្រះមួយណាសំរាប់ដើរតាម (យ៉ូស្វេ ២៤:១៤-១៥) ការត្រាស់ហៅរបស់ព្រះជាម្ចាស់ឲ្យធ្វើការសម្រេចចិត្ត រវាងព្រះយ៉ាវេ និង ព្រះបាល (១ ពង្សាវតា ១៨:២១) ការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ដែលស្អប់ជំនឿក្ដៅមិនក្ដៅ ត្រជាក់មិន ត្រជាក់ (វិវរណៈ ៣:១៥-១៦) ។*

អ័រប៉ា បានជ្រើសរើសយកផ្លូវមួយ ដោយពឹងផ្អែកលើការយល់ឃើញ និង ការវិភាគរកហេតុផលរបស់មនុស្ស ដែលគេហៅថា "ការដើរដោយការមើលឃើញ មិនមែនការដើរដោយជំនឿ"ឡើយ(គឺផ្ទុយគ្នាជាមួយនឹង២កូរិនថូស៥:៧) ។ យើងមិនបានឮគេនិយាយអំពីនាងអ័រប៉ាឡើយ ។ នាងរស់ធ្វើការជ្រើសរើសផ្ទុយពីនាងអ័រប៉ា ហើយនិងមិនយូរប៉ុន្មានការល្អទាំងអស់នាងបានទទួលនូវការសប្បាយរីករាយចំពោះការដែលនាងសម្រេចចិត្តនោះ ។ ទោះបីជាមិនឃើញមានអ្វីជាទីសង្ឃឹមយ៉ាងណាក៏ដោយនាងរស់នៅតែសម្រេចចិត្តទៅតាមណាអូមី និង ទុកចិត្តដល់ព្រះយ៉ាវេ ហើយការសម្រេចចិត្តនោះធ្វើឲ្យព្រឹត្តិការណ៍វិលទៅមុខទៅរកការល្អគ្រប់យ៉ាង ដែលនាងបានទទួលការសប្បាយរីករាយយ៉ាងឆាប់ នៅក្នុងការសម្រេចចិត្តរបស់នាង ។

## កិច្ចការនៃជំនឿ (ជំពូក ២)

ប៉ុន្តែតើជំនឿចប់ត្រឹមតែការសម្រេចចិត្ត ឬក៏គ្រាន់តែនិយាយខ្ញុំសម្រេចចិត្តហើយឬយ៉ាងណា? តើការសម្រេចចិត្តទុកចិត្តព្រះជាម្ចាស់មានន័យថា អ្នកជឿថ្មីនោះត្រូវអង្គុយរង់ចាំឲ្យព្រះធ្វើការជំនួសឬយ៉ាងណា? តើយើង"អះអាង" ចង់បានព្រះពររបស់ព្រះជាម្ចាស់ ហើយចាំឲ្យព្រះផ្តល់ឲ្យយើងតាមបែបមួយដ៏អស្ចារ្យឬ? តើជំនឿ មិនចាំបាច់អ្វីឲ្យយើងធ្វើការកាងារឬអី?

ចំពោះនាងរស់មិនដូច្នេះឡើយ ។ នាងបានធ្វើតាមពាក្យសំដីរបស់នាងដោយព្រមដើរតាមណាអូមី ទៅបេថ្លេហិមនៅក្នុងស្រុកយូដា នៅក្នុងខណៈដែលរដូវស្រូវឱកកំពុងចាប់ផ្តើមប្រមូលផល (១:២២) ។ ស្រូវឱកជារឿយៗ គេតែងគិតថាស្រូវឱកស្រាលជាងស្រូវសាឡី [៦]គេប្រមូលផលស្រូវឱកនៅក្នុងខែមេសា-ឧសភា ឯស្រូវសាឡីវិញ គេប្រមូលផលនៅពីរបីអាទិត្យក្រោយមក ។ នាងរស់មិនរង់ចាំឲ្យព្រះបំពេញសេចក្តីត្រូវការរបស់ម្តាយក្មេករបស់នាងមក តាមបែប

---

*[៦] ឧទាហរណ៍ ស្រូវឱក មានតម្លៃថោកជាងស្រូវសាឡីពីរដង នៅក្នុង ២ពង្សាវតាក្សត្រ ៧:១ ថោកជាងបីដង នៅក្នុង វិវរណៈ ៦:៦ ការប្រៀបធៀបរបស់ គីឌាន និង អ៊ីស្រាអែល ចំពោះ "ដុំនំបុ័ងមូល ដែលធ្វើអំពី ស្រូវឱក" នៅក្នុង ចៅហ្វាយ ៧:១៣ ដែលជានិមិត្តសញ្ញាយ៉ាងច្បាស់ ពីភាពទន់ខ្សោយរបស់គេចំពោះសាសន៍ម៉ាឌាន ។*

អស្ចារ្យនោះឡើយ ។ នាងរស់ស្នើសុំទៅរើសកួរស្រូវឱកនៅឯវាលស្រែ ។ គឺថា នៅខណៈដែលគេច្រូតស្រូវចងជាកណ្ដាប់ តែមានកួរស្រូវខ្លះត្រូវបាក់ធ្លាក់មកដី ក៏គេច្រូតមិនអស់ ។ ក្រិត្យវិន័យនៅគម្ពីរសញ្ញាចាស់បានពណ៌នាថា កួរស្រូវបែបនេះត្រូវទុកសំរាប់"ពួកអ្នកក្រ និងពួកអ្នកមកពីក្រៅស្រុក"[៧] ។ ច្បាប់ដ៏ប្រពៃនេះផ្ដល់ឲ្យអ្នកក្រ និង ជួយលើកទឹកចិត្តឲ្យគេរក្សាភាពថ្លៃថ្នូររបស់ពួកគេ ដោយទុកឱកាសឲ្យគេធ្វើការមុនពេលទទួលទានអាហារ មិនមែនគ្រាន់តែដើរសុំទានគេនោះឡើយ ។ ការនេះការពារការអាក្រក់ពីរយ៉ាង មិនឲ្យកើតមានឡើងគឺ មិនឲ្យពួកអ្នកមានកំណាញ់ហួសហេតុពេក និង មិនឲ្យអ្នកក្របានទទួលអាហារដោយស្រួលពេក ដោយមិនបានបញ្ចេញពលកម្មនោះដែរ ដែលជាហេតុនាំឲ្យបាត់បង់ភាពថ្លៃថ្នូររបស់ខ្លួន ។ ការរើសកួរស្រូវ គឺជាការលំបាកណាស់ គឺជាការងារដែលត្រូវចេះបន្ទាបខ្លួន ជាទូទៅការងារនោះវាមិនបានផលច្រើនណាស់ណានោះឡើយ តែវាអាចផ្ដល់ឲ្យបានផលខ្លះ ។ នាងរស់ព្រមបន្ទាបខ្លួន និង ប្ដូរផ្ដាច់ស្ម័គ្រចិត្តធ្វើការងារនៃការស្វែងរកនូវការអនុញ្ញាត (២:២,៧) សុំរើសកួរស្រូវឱក ។ ក្នុងការធ្វើដូច្នេះនាងមិនបានបង្ហាញឲ្យឃើញថា នាងខ្វះជំនឿចំពោះព្រះថ្មីរបស់នាងឡើយ ក្នុងការដែលព្រះអង្គផ្ដល់មកឲ្យនាងនូវអ្វី ដែលនាងត្រូវការនោះ ប៉ុន្តែនាងបង្ហាញពីជំនឿដ៏រស់[៨] ដែលនាងធ្វើតាមផ្លូវដែលព្រះជាម្ចាស់ អង្គនេះបានផ្ដល់នូវការផ្គត់ផ្គង់ដល់សេចក្ដីត្រូវការរបស់នាង ។ នាងមិនគ្រាន់តែធ្វើការប៉ុណ្ណោះទេ តែនាងធ្វើការយ៉ាងយូរ និង លំបាកទៀតផង (២:៧, ១៧, ១៨, ២៣)[៩] ។

---

[៧] *លេវីវិន័យ ១៩:៩-១០; ២៣:៣២ ចោទិយកថា ២៤:១៩-២២ ។ បូអូសបានធ្វើហួសពីច្បាប់តម្រូវឲ្យធ្វើ (២:១៥-១៦; ៣:១៥) ។ លទ្ធផលនោះគឺ នាងរស់ត្រឡប់មកផ្ទះបានស្រូវច្រើនហួសពីការ ដែលនាងរើសកួរស្រូវធម្មតាទៅទៀត គឺប្រហែលជា មួយថាំង (២:១៧) ។ ហេតុដូច្នេះ នាងរើសមួយថ្ងៃអាចចិញ្ចឹមស្ត្រីពីរនាក់រហូតបានបីអាទិត្យឯណោះ ។ ចំនួនដ៏ច្រើននេះ ធ្វើឲ្យណាអូមី សួរដល់នាងរស់ ហើយនិងសុំឲ្យព្រះជាម្ចាស់ប្រទានពរដល់ម្ចាស់ស្រែ ទោះបីជាមិនទាន់បានដឹងថាអ្នកនោះជាអ្នកណាក៏ដោយ ។ (២:១៨-១៩)។*

[៨] *សូមមើល យ៉ាកុប ២:១៤-២៦*

[៩] *រដូវច្រូតកាត់ដែលមានលើកមកនិយាយក្នុង ២:២៣ មានរយៈពេលដែលប្រហែលប្រាំពីរអាទិត្យ*

ដោយមិនគ្រោងទុកជាមុនសោះ នាងរស់បានជ្រើសរើសស្រែដែលជាកម្មសិទ្ធិរបស់ បូអូស ជាសាច់ញាតិដ៏គួរឲ្យគោរពរាប់អានរបស់អេលីម៉ាឡេក (២:១,៣,២០) ។ តាមការប្រាស្រ័យទាក់ទងរវាងគាត់ និងអ្នកចម្រូតរបស់គាត់(២:៤)បង្ហាញឲ្យយើងដឹងថា គាត់មានចរិតសប្បុរស និង កោតខ្លាចព្រះ ។ ទោះបីជានៅក្នុងយុគសម័យងងឹត ក្រោមការដឹកនាំរបស់ពួកចៅហ្វាយ ក៏នៅមានមនុស្ស ដែលកោតខ្លាចព្រះជាម្ចាស់ ហើយនិងថ្វាយព្រះកិត្តិយសដល់ព្រះអង្គដែរ ។ ក្រោយមកយើងឃើញថាគាត់ជាមនុស្សសប្បុរស (២:១៤-១៦; ៣:១៥) ស្មោះត្រង់ (៣:១៨) នឹងធឹង និង ឧស្សាហ៍ធ្វើការងារ (៤:១-១០) ។ គាត់សង្កេតមើល និងសាកសួរអំពីនាងរស់ ហើយនិងផ្តល់ឲ្យនាងដោយចិត្តសប្បុរស នៅពេលដែលគាត់ដឹងថានាងរស់ជានរណាហើយនោះ ។ គាត់ធ្វើដូច្នេះ ពីព្រោះមានគេប្រាប់គាត់ពីកិច្ចការនៃជំនឿរបស់នាង ពីរបៀបដែលនាងមកពឹងជ្រកនៅក្រោមចំអេងស្លាបរបស់ព្រះយ៉ាវេ ហើយខំធ្វើការបំរើដល់ម្តាយក្មេក (២:១១-១២) ។ គាត់អធិស្ឋានសុំឲ្យព្រះជាម្ចាស់ប្រទានពរដល់នាង (២:១២) ដោយដឹងតិចៗថាគាត់នឹងអាចជាផ្លូវមួយដែលអាចនាំព្រះពរចុះមកបាន ។ គាត់បានជំរុញឲ្យនាងរស់ ស្នាក់នៅស្រែរបស់គាត់ និង នៅជាមួយអ្នកច្រូតរបស់គាត់ដោយយល់ដល់សុវត្ថិភាពរបស់នាង(២:៨-៩)-ណាអូមីក៏ជំរុញឲ្យនាងរស់ រើសកួរស្រូវនៅស្រែរបស់បូអូសតទៅទៀតដែរ ដើម្បីចៀសវាងកុំឲ្យមនុស្សអាក្រក់ធ្វើបាប(២:២២) ។

**ការស្នើសុំដោយជំនឿ** (ជំពូក ៣)

ជំនឿអាចរឹងមាំបានក្នុងការសម្រេចចិត្ត ដែលផ្ទុយស្រឡះពីការវិនិច្ឆ័យផ្ទាល់ខ្លួន ហើយបន្ទាប់មកអនុវត្តនូវការសម្រេចចិត្តយ៉ាងម៉ត់ចត់ ប៉ុន្តែជំនឿតាមព្រះគម្ពីរ គឺមិនរីករាយជាមួយនឹងអ្វី ដែលយើងសម្រេចបានតែមួយមុខប៉ុណ្ណោះទេ ។ ជំនឿគឺទទួលស្គាល់ពីសេចក្តីត្រូវការ ហើយនិង ទូលសុំឲ្យព្រះជាម្ចាស់ធ្វើការអ្វី ដែលមិនអាចធ្វើបាន ។

កាលពីដំបូងណាអូមី បានអធិស្ឋានសុំព្រះជាម្ចាស់ឲ្យព្រះអង្គផ្តល់ការសំរាកដល់កូនប្រសារស្រីរបស់គាត់ នៅក្នុងផ្ទះរបស់ប្តីម្នាក់ផ្សេងទៀត (១:៩)

ដូចជាមិនទំនងសោះចំពោះនាងរស់ ដែលនាងជាជនស្រុកក្រៅ[១០] ដែលអាចនាំព្រះពរមកស្រុកយូដាយ៉ាងច្រើនម្ល៉េះ ។ ប៉ុន្តែឥឡូវនេះ ដោយសារសេចក្តីត្រូវការផ្ទាល់របស់គាត់បានសម្រេច និង សេចក្តីសង្ឃឹមបានកែប្រែជាថ្មីឡើង ណាអូមីបង្វែរគំនិតរបស់គាត់ ពីការទុក្ខព្រួយដ៏ល្វីងជូរចត់ចំពោះកូនប្រសារស្រីរបស់គាត់ ហើយក៏មានគំនិតថា គាត់នឹងត្រូវស្វែងរក "ការសំរាក"[១១] ឲ្យនាងរស់ (៣:១) ។ ម្នាក់ ដែលគាត់ត្រូវស្វែងរកនោះគឺ បូអូស ដែលគាត់បានបង្ហាញពីភាពសប្បុរសរបស់គាត់ ចំពោះនាងរួចទៅហើយ ។

តាមច្បាប់របស់ពួកយូដា បានបង្ហាញថា បើបងប្អូនប្រុសរស់នៅជាមួយគ្នា ហើយមានម្នាក់ស្លាប់ហើយគ្មានកូនប្រុស បងប្អូនប្រុសដែលនៅរស់នោះ ត្រូវរៀបការជាមួយស្ត្រីមេម៉ាយនោះ ។ កូនទីមួយដែលបានកើតមកនោះ ត្រូវដាក់ឈ្មោះតាមត្រកូលអ្នកស្លាប់ (ចោទិយកថា ២៥:៥-១០) ។ ទម្លាប់នេះហើយដែលធ្វើឲ្យពួកសាឌូស៊ីចោទសួរដល់ព្រះយេស៊ូនៅក្នុង ម៉ាថាយ ២២:២៣-៣៣ ហើយ និង ការចាក់បណ្តោយស្របទៅនឹងខគម្ពីរនោះ ។ ដោយបង្ហាញត្រួសៗ តាមផែនការនៃជំពូក ៣:៣-៤ ណាអូមី បានជំរុញឲ្យនាងរស់ឲ្យទៅសុំបូអូសបង្ហាញពីភាពទទួលខុសត្រូវ ក្នុងការដែលគាត់អាចរៀបការជាមួយនាងបាន។ ការត្រដាងសំលៀកបំពាក់របស់នរណាម្នាក់គ្របទៅម្នាក់ទៀត (៣:៩) គឺមានន័យថា ជាការស្នើសុំរៀបការ ដូចនៅក្នុងអេសេគាល ១៦:៨ ។

រឿងនេះអាចធ្វើឲ្យអ្នកអានភ្ញាក់ផ្អើល ព្រោះវាចំៗពេក ប៉ុន្តែជំនឿគឺព្រមបន្ទាបខ្លួន និងហ៊ានសុំចំពោះការធំ ។ ការទទូចយ៉ាងខ្លាំងរបស់ស្ត្រីម្នាក់នៅក្នុង (ម៉ាថាយ ១៥:២១-២៨ ; ម៉ាកុស ៧:២៤-៣០) គួសបញ្ជាក់បន្ថែមលើសេចក្តីពិតនោះ ។ ចំពោះនាងរស់ កិច្ចការនៃជំនឿរបស់នាងបានក្លាយទៅជាការផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់នាងផ្ទាល់ និង របស់ណាអូមីផង គឺនាងបានធ្វើដោយ

---

*(១០) ខគម្ពីរយោងលើកយកមកនិយាយពីនាងរស់ ដែលជាសាសន៍ "ម៉ូអាប់"នៅក្នុងកណ្ឌគម្ពីរទាំងមូល (១:២២; ២:២, ៦, ២១; ៤:៥, ១០) ដែលបាននិយាយសង្កត់ធ្ងន់ថា នាងជាសាសន៍ដទៃ ។*

*(១១) ភាសាហេព្រើ បានបកប្រែថា "សំរាក" គឺជានិមិត្តសញ្ញាបញ្ជាក់ថា បានស្នាក់នៅក្នុងកន្លែងពិសេសណាមួយ ។ គឺជាកន្លែង ដែលត្រូវកសាងជីវិត គឺជាផ្ទះ ដែលគេចង់និយាយពីកន្លែងមានសន្តិសុខ មិនមែនជាការលំហែកាយនោះទេ ។*

ចិត្តក្លាហាន នាងស្មើដោយជំនឿឥតមានស្ទាក់ស្ទើរ ជាហេតុនាំឲ្យកិច្ចការជាច្រើនបានសម្រេចចំពោះរូបនាង ។

"លានបោកស្រូវ" គឺជាកន្លែងដែលគេលើកឡើងឲ្យខ្ពស់បន្តិច ធ្វើឲ្យរាបស្មើ ដោយរៀបថ្ម ឬ បុកបង្ហាប់ដី តាមធម្មតាស្ថិតនៅខាងកើត ឬ នៅក្រោមខ្យល់ពីទីក្រុង ។ អ្នកច្រូតផាត់ចំបើង រោយស្រូវនៅពេលមានជំនោរបក់មក ដែលតាមធម្មតាបក់មកពីសមុទ្រ មេឌីតេរ៉ាណេ នៅពេលរសៀល ។ អង្កាម ឬ សំដីស្រូវប៉ើងខ្ទាត់ខ្ទាយទៅ ប៉ុន្តែគ្រាប់ស្រូវដែលមានជាក់គ្រាប់នោះត្រូវធ្លាក់នៅ លើដីដើម្បីឲ្យគេអាចប្រមូលកើបដាក់ជង្រុក ។ ចំណែកឯ បូអូស ដ៏ជាមនុស្ស សាមញ្ញដែលមិនប្រកាន់ខ្លួនបានសំរាន្តនៅឯលានបោកស្រូវ មិនដឹងថាគាត់សំរាន្តយាមស្រូវ ឬ សំរាន ដោយមានពិធីបុណ្យអ្វីឡើយ ។ ទោះជាយ៉ាងណាក៏ ដោយមានអ្នកបកស្រាយខ្លះ បានឃើញពីភាពឲ្យដៃ នៅក្នុងទង្វើរបស់នាងរស់ ដែលបានបើក "ភួយចុងជើងរបស់ បូអូស" ។ សេចក្ដីថ្លែងការណ៍របស់ បូអូស នៅក្នុង ៣:១១ ដែលបង្ហាញឲ្យដឹងថា នាងរស់ ជាស្ត្រីមានចរិតល្អ ដូចជាតួអង្គ សំខាន់នៅក្នុងរឿងទាំងមូលដែរ គេបានប្រកែកប្រឆាំងចំពោះការប៉ាន់ស្មានបែបនេះ ។ នាងរស់គឺគ្រាន់តែព្រមសុំឲ្យបូអូស បង្ហាញពីកាតព្វកិច្ចរបស់គាត់ក្នុងនាមជាសាច់ញាតិដែលអាចជួយសង្គ្រោះនាងបាន ។ ការដែលនាងងូតទឹកសំអាតខ្លួន លាបទឹកអប់ និង ស្លៀកពាក់ស្អាតបាត (៣:៣) តាមពិតទៅមិនមែនមានបំណងចង់បង្អាក់ការឆ្លើយតបរបស់គាត់ចំពោះនាងនោះឡើយ ។

មិនថាឡើយនាងដឹង ឬ មិនបានដឹងថា អេលីម៉ាឡេក មានសាច់ញាតិជិតៗជាង បូអូស ដែលមានសិទ្ធិនឹងទិញដីរបស់គាត់ និង អាចយកនាងរស់ ធ្វើជាប្រពន្ធរបស់គាត់ ។ បូអូស ភ្ញាក់ក្រញ្ញាងទាំងកណ្ដាលយប់ នៅពេលដែលគាត់ដេកនៅឯលានបោកស្រូវ ភ្ញាក់ឡើងឃើញស្ត្រីម្នាក់នៅចុងជើងរបស់គាត់ ។ គាត់បានស្គាល់ពីអត្តសញ្ញាណរបស់នាង និង បានឮពីសំណើរបស់នាង បូអូសបានស្នើដល់នាងរស់ថា នៅពេលព្រឹកឡើង គាត់នឹងប្រាប់សាច់ញាតិម្នាក់ទៀត ដែលអាចជួយលោះនាងបាន ហើយបន្ទាប់មកបើសាច់ញាតិម្នាក់នោះ គេមិនព្រមប្រើសិទ្ធិរបស់គេ ដើម្បីលោះនាងទេ គាត់សន្យាថានឹងលោះនាង ដោយខ្លួនឯង ។ បន្ទាប់មកគាត់បានប្រាប់ឲ្យនាងរស់ដេកលក់ទល់ភ្លឺ ហើយមុនពេលនាងចាកចេញទៅ គាត់បានឲ្យស្រូវឱកទៅនាង ៦ រង្វាល់ (មួយតៅ) ។

ណាអូមី ចង់ដឹងឮយ៉ាងខ្លាំងថា តើរឿងរ៉ាវនោះទៅជាយ៉ាងណាហើយ ។ នៅពេលដែលគាត់ឮរឿងរ៉ាវ ដែលនាងរស់រៀបរាប់ប្រាប់ និង ឃើញស្រូវដែលបូអូស ផ្ញើមកឲ្យគាត់ គាត់បានលើកទឹកចិត្តឲ្យនាងរស់រង់ចាំមើលលទ្ធផលជាយ៉ាងណា ថែមទាំងអះអាងថា បូអូសនឹងប្រកាន់តាមពាក្យសន្យារបស់គាត់ ។ នៅថ្ងៃនេះឯង គាត់នឹងធ្វើការនោះ ។

ដូច្នេះសំណើនៃជំនឿ បានក្លាយជាការសំរាកនៃជំនឿ ។ ជំនឿធ្វើឲ្យហ៊ានសុំកិច្ចការធំៗ សូម្បីតែភ្នំក៏អាចរើបានដែរ (ម៉ាថាយ ២១:-២២) ហើយបន្ទាប់មកយើងសំរាកក្នុងជំនឿ ដែលទុកឲ្យព្រះធ្វើការនោះជំនួសយើង ។ ការនេះធ្វើឲ្យយើងនឹកឃើញដល់ស្តេច យេហូសាផាត ដែលបានទូលអង្វរដល់ព្រះជាម្ចាស់ប្រឆាំងនឹងកងទ័ពចំរុះ ដែលបានដើរជាក្បួនមកប្រឆាំងទាស់នឹងទ្រង់ ហើយពេលនោះ ស្តេចយេហូសាផាត បានទទួលបញ្ជាថាឲ្យសំរាក និង រង់ចាំ ការដែលព្រះជាម្ចាស់រំដោះឲ្យរួចពីដៃសត្រូវ (២ របាក្សត្រ ២០) ។ នាងហាណាអធិស្ឋានទូលសូមកូនប្រុស ហើយបន្ទាប់មកក៏សំរាកក្នុងជំនឿ សំរាប់ចម្លើយរបស់ព្រះជាម្ចាស់ "បានចេញទៅ ហើយនិងទទួលទានចំណីអាហារខ្លះ និង ទឹកមុខរបស់គាត់បាត់ទុក្ខព្រួយ" (១សាំយូអែល ១:១៨) ។ អ្នកទាំងនេះ និង អ្នកដទៃទៀតបានស្មើចំពោះព្រះជាម្ចាស់ មិនសុំព្រះជាម្ចាស់សំរាប់របស់អ្វីមួយ ដោយបំណងអាត្មានិយមរបស់ខ្លួនច្រើនហួសហេតុ ប៉ុន្តែយើងសុំសំរាប់របស់អ្វី ដែលជាសេចក្តីត្រូវការចាំបាច់ ដែលស្របជាមួយនឹងសេចក្តីសញ្ញារបស់ព្រះអង្គ ហើយនិងបន្ទាប់មកសំរាកដោយសង្ឃឹមរង់ចាំទទួលចម្លើយពីព្រះអង្គ ។ នៅមានទៀតសំខាន់បំផុតគឺត្រូវចងចាំពី សំណើរបស់នាងរស់ គឺនាងធ្វើតាំងពីការសម្រេចចិត្តដោយជំនឿ និង ការធ្វើការដោយជំនឿរបស់នាង និងនាងមិនបានផ្តេកផ្តួលលើភាពខ្ជិលច្រអូសឬគេចវេះពីភាពទទួលខុសត្រូវ និង សេចក្តីត្រូវការរបស់ជីវិតរស់នៅឡើយ ។ សំណើរបស់នាងបានធ្វើឡើងស្របតាមសេចក្តីសន្យារបស់ព្រះជាម្ចាស់ដែលមាននៅក្នុងក្រឹត្យវិន័យ ប៉ុន្តែគឺវាហួសពីសមត្ថភាពរបស់នាង ដែលអាចធ្វើការងារនោះឲ្យកើតឡើងដោយខ្លួនឯងបាន ។

## វគ្គាន់នៃជំនឿ (ជំពូក ៤)

នៅក្នុងជំពូក ៤ យើងឃើញថា បូអូស ខំប្រឹងធ្វើការទាល់តែបានសម្រេចតាមសេចក្តីសន្យារបស់គាត់ ។ គាត់នឹងធ្វើកិច្ចការគ្រប់យ៉ាងទាំងអស់ ដោយប្រើកម្លាំង ភាពមានសីលធម៌ និង ភាពម៉ត់ចត់បំផុតរបស់គាត់ ។

"ច្រកទ្វារទីក្រុង" (៤:១) គឺជាមណ្ឌលសាធារណៈសំរាប់មនុស្សធ្វើជំនួញទូទៅ ធ្វើការដោះដូរ និងផ្តល់ការវិនិច្ឆ័យផ្សេងៗ[១២] ។ បូអូសបានទៅទ្វារ ទីក្រុង ហើយនៅពេលដែលសាច់ញាតិជិតដិតរបស់គាត់បានដល់ គាត់បាននាំម្នាក់នោះទៅកាន់បន្ទប់"កាត់ក្តី" ។ បន្ទាប់មកគាត់អញ្ជើញចាស់ទុំគម្រប់ដប់នាក់មកធ្វើជាសាក្សីនៅក្នុងពេលពិភាក្សារបស់គាត់ ។ នៅពេលដែលពួពាក្យសំដីរបស់ បូអូស ដែលថាអេលីម៉ាឡេកមានទ្រព្យសំរាប់លក់ ។ សាច់ញាតិជិតដិតនោះ បានបង្ហាញពីការចាប់អារម្មណ៍ដោយស្ទួររករបស់នោះ ។ ប៉ុន្តែនៅពេលដែល គាត់បានដឹងថារឿងនោះទាក់ទងទៅនឹងការរៀបការជាមួយនាងរស់ និងការបន្តពូជពង្សឲ្យអេលីម៉ាឡេក គាត់ក៏ប្រកែកភ្លាម ។ បន្ទាប់ក្រោយមក មានការពណ៌នា ពីទំលាប់ដែលបានក្លាយជាទំនៀមទំលាប់តាំងពីយូរណាស់មកហើយ ដែលត្រូវឲ្យមានការពន្យល់នៅចំពេល ដែលកណ្ឌគម្ពីរនេះបានសរសេរឡើង ចំពោះការដែលប្រគល់ស្បែកជើងឲ្យ គឺបង្ហាញពីភាពស្របច្បាប់ក្នុងការធ្វើការជួញដូរ(៤:៧-៨) ។ បន្ទាប់មក បូអូស បញ្ជាក់ថា គាត់មានបំណងនឹងលោះស្រែអំពកនោះ និង ព្រមរៀបការជាមួយនាងរស់ ដោយបញ្ជាក់យ៉ាងមុតមាំ និង ច្បាស់លាស់ដូច ដែលនាងរស់សម្រេចចិត្តចាកចោលស្រុកម៉ូអាប់ និង ព្រមតាម ណាអូមី ដូច្នេះដែរ (៤:៩-១០ ជំពូក ១:១៦-១៧)[១៣] ចាស់ទុំទាំងដប់នាក់បានបញ្ជាក់ថា គេបានធ្វើជាសាក្សីចំពោះការដោះដូរនេះដោយព្រលយពាក្យ ប្រាប់ឲ្យដឹងថាគ្រប់យ៉ាងទាំងអស់មានសណ្តាប់ធ្នាប់ត្រឹមត្រូវ ។ ពួកគេអធិស្ឋានសុំព្រះពរសំរាប់ការស្នើសុំការរៀបការនេះ ហើយគេអធិស្ឋានសូមឲ្យពួកគេឆាប់មានកូន ។ មិនយូរប៉ុន្មាន ព្រះអម្ចាស់

---

(១២) *សូមមើល ឧទាហរណ៍ លោកុប្បត្តិ ២៣:១០,១៨; ៣៤:២០,២៥; ចោទិយកថា ១៧:១៥; ២១:១៩; ១៥,២៤; ២៥:៧ ហើយនិងនៅទូទាំងគម្ពីរសញ្ញាចាស់ទាំងមូល ។*

(១៣) *ដូចជា បូអូស មានចិត្តមិនគិតពីអាត្មានិយម ចរិតស្មោះត្រង់ ស្របគ្នានឹងនាងរស់ ដូច្នេះសាច់ញាតិដែលមានសិទ្ធិលោះនាងបាន គេប្រកែកមិនព្រម ព្រោះអ្នកនោះមានចរិតគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន និងធ្វើអ្វីៗតាម "ការវិនិច្ឆ័យតាមក្បួនខ្នាត" ចរិតលក្ខណៈនេះស្របទៅ នាង អ័រប៉ា ។*

ឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់គេទាន់ពេល ។ នាងរស់ក៏មានផ្ទៃពោះ(៤:១៣) និងកើតបានកូនប្រុសមួយ ។

ឥឡូវនេះ សម្បត្តិរបស់ណាអូមី បានមកពេញលេញដូចមុនវិញហើយ។ គាត់បានចាកចេញពីយូដាទៅដោយពេញពោរ ដល់ត្រឡប់មកវិញទទេ (១:២១) ហើយឥឡូវនេះគាត់បានទទួលពេញពោរឡើងវិញទៀតហើយ ។ ស្ត្រីដែលមានឈ្មោះ “រីករាយ” ដែលបានសន្និដ្ឋានថាជាចំណាស់ជើងដែល “ជូរចត់” នោះ ឥឡូវនេះ បែរជាមានសេចក្តី “រីករាយ” ដោយមានអ្នកជួយលោះ ដែលជួយឲ្យជីវិតរបស់គាត់បានកែប្រែជាថ្មី និងជួយគាំទ្រជីវិតរបស់គាត់ កាលដែលគាត់ចាស់ហើយនោះ (៤:១៥)[១៤] ។ ណាអូមី បានលើកកូនតូចមកដាក់លើភ្លៅ ហើយបីបមថ្នមថែកូនក្មេងនោះ (៤:១៦) ។ គ្រប់ការទាំងអស់នេះ គឺដោយសារតែព្រះពររបស់ព្រះជាអម្ចាស់ ដែលបានប្រទានពរមកដល់គាត់ ដោយព្រោះគាត់បានវិលត្រឡប់មកកាន់ទឹកដីសន្យាហើយនិងដោយសារតែ ការងារនៃកូនប្រសារស្រីដ៏ស្មោះត្រង់ ដែលគ្រាន់បើជាងកូនប្រុស ៧ នាក់ ទៅទៀត (៤:១៥)[១៥] ។

បញ្ជីរៀបរាប់ពីពង្សាវតា ដែលបានបង្ហាញពីភាពដ៏មានសារសំខាន់ និងហួសពីការដែលយើងអាចគិតដល់ ចំពោះការសម្រេចចិត្ត កិច្ចការ និងសំណើដោយជំនឿរបស់នាងរស់ ។ ប៉េរេសដែលមានពង្សាវតាចាប់ផ្តើមនៅក្នុង (៤:១៨) ជាកូនរបស់យូដា[១៦] ដែលព្រះជាម្ចាស់បានសន្យានឹងផ្តល់ឲ្យមានអ្នកដឹកនាំមកយ៉ាកុប[១៧]នោះ ។ មែនហើយអូបិឌជាកូនរបស់បូអូសនិងនាងរស់ហើយកូននោះ

---

(១៤) *នៅខាងដើមនៃកណ្ឌគម្ពីរនេះ គេបានពិចារណាឃើញថា បូអូស ជាសាច់ញាតិដែលអាចលោះនាងរស់បាន ។ ប៉ុន្តែ ឥឡូវនេះនៅក្នុងជំពូក ៤:១៤-១៥ ចំណាស់ជើងនោះ គេបានយកមកប្រើចំពោះកូនក្មេងដែលបានកើតមកពី បូអូស និងនាងរស់ ផងដែរ ។ អូបិឌ នឹងដើរតួជា “អ្នកសង្គ្រោះឬអ្នកលោះ” ណាអូមីឲ្យរួចពីភាពទទេស្អាត ភាពមិនសំខាន់ និង ភាពគ្មានក្តីសុខនោះទៅវិញ ។*

(១៥) *ការនេះគឺជាការ ដែលទទួលបានសេចក្តីកោតសរសើរខ្លាំងណាស់ នៅក្នុងសម័យនោះ កូនប្រុសហាក់ដូចជាមានតម្លៃខ្លាំងជាងកូនស្រី ។*

(១៦) *លោកុប្បត្តិ ៣៨ បានថែងប្រាប់ពីរឿងចាប់កំណើត និងការកើតរបស់ប៉េរេស ។ (លោកុប្បត្តិ ៤៦:១២)*

(១៧) *លោកុប្បត្តិ ៤៩:១០*

ក្លាយជាឪពុករបស់អ៊ីសាយ ហើយនិង អ៊ីសាយជាឪពុករបស់ដាវីឌ ជាស្តេចនៃអ៊ីស្រាអែល និងជាពូជពង្សវង្សត្រកូល ដែលព្រះយេស៊ូជាព្រះមេស្ស៊ីយាងមកចាប់ កំណើតជាមនុស្ស[១៨] ។ តើនរណានឹងដឹងបានថាវាសំខាន់យ៉ាងម៉េចនោះចំពោះការសម្រេចចិត្ត កិច្ចការ និង សំណើដោយជំនឿរបស់មនុស្សម្នាក់នោះ? តើនរណាអាចដឹងបានថាតើរង្វាន់នៃជំនឿនោះធំប៉ុណ្ណាឡើយ សំរាប់មនុស្សដែលបានទទួលការនោះ? នាងរស់មិនគ្រាន់តែបានទទួលព្រះពរ ដោយបាន "សំរាក" នៅក្នុងផ្ទះមានប្តីមានកូន តែនាងរីករាយចំពោះការគោរពរាប់អាន ចំពោះអស់អ្នកដែលបានស្គាល់នាងតែប៉ុណ្ណោះទេ (៣:១១; ៤:១៥) គឺនាងថែមទាំងបានក្លាយទៅជាពូជពង្សវង្សត្រកូល ដែលព្រះមេស្ស៊ី នឹងមកចាប់កំណើត ។ ការទាំងអស់នេះគឺសំរាប់ជនបរទេសដែលបានដាក់ជំនឿរបស់ខ្លួន ជឿដល់ព្រះជាម្ចាស់នៃអ៊ីស្រាអែល និងធ្វើការប្រព្រឹត្តិតាមជំនឿនោះ[១៩] (គឺនឹងបានដូចជា នាងរស់ដែរ) ។

### ការពិចារណាដទៃផ្សេងទៀត

ដូចដែលបានជំរាបពីខាងដើមរួចមកហើយថា អត្ថបទនេះមិនបានមានបំណងពន្យល់ឲ្យស៊ីជម្រៅនៃកណ្ឌគម្ពីរនាងរស់ទេ ប៉ុន្តែគ្រាន់តែផ្តល់ការណែនាំ

---

[១៨] *ការរាប់ នាងរស់ ជាសាសន៍ ម៉ូអាប់ បញ្ចូលក្នុងវង្សត្រកូលរបស់គាត់ អាចជួយពន្យល់ពីហេតុអ្វីបានជាការនេះកើតឡើងបាន ដ្បិតអី ពួកម៉ូអាប់ គឺធ្លាប់ជាខ្មាំងសត្រូវរបស់អ៊ីស្រាអែល (១ សាំយូអែល ១២:៩; ១៤:៤៧) ព្រះបាទដាវីឌ បាននាំយកឪពុកម្តាយរបស់ទ្រង់ទៅលាក់នៅឯម៉ូអាប់ ព្រោះខ្លាចស្តេចសូលធ្វើបាបក្នុងពេលដែលស្តេចសូលដេញតាមនោះ (១ សាំយូអែល ២២:៣-៤) ។*

[១៩] *បញ្ជីរាយនាមពង្សាវតានៃព្រះយេស៊ូ នៅក្នុងម៉ាថាយ ១បានចុះបញ្ជីស្ត្រី ៤ នាក់ ក្នុងចំណោមស្ត្រីទាំងបួននាក់ ក្នុងចំណោមស្ត្រីទាំងបួន គ្មានស្ត្រីណាម្នាក់ ដែលគួរឲ្យគោរព ឬគួរផ្តល់កិត្តិយសឡើយ ។ នាងតាម៉ាជាកូនប្រសាររបស់យូដា និង យូដាមានទំនាក់ទំនងជាមួយនាងជាអំពើអសីលធម៌ (លោកុប្បត្តិ ៣៨)។ នាងរ៉ាហាបជាស្រីបរទេសម្នាក់មកពីទីក្រុង យេរីខូ ដែលខូចបាក់ ហើយមានអ្នកបកស្រាយជាច្រើនថានាងជាស្រីសំផឹង ។ នាងរស់ជាស្រីបរទេសម្នាក់ និងជាសាសន៍ម៉ូអាប់ ដែលហេតុការណ៍នោះ គេបានលើកមកបញ្ជាក់ម្តងហើយម្តងទៀត នៅក្នុងកណ្ឌគម្ពីរទាំងមូល (ចូរសង្កេតមើល នៅក្នុងកំណត់ចំណាំទំព័រក្រោម ត្រង់លេខ ១០) ។ ចោទិយកថា ២៣:៣ បានបញ្ជាក់ថា គ្មានសាសន៍ម៉ូអាប់ណាម្នាក់អាចអនុញ្ញាតឲ្យចូលទៅក្នុងរួមប្រជុំនៃព្រះយ៉ាវេបានឡើយ សូម្បីតែដប់ជំនាន់ក្រោយមកទៀត ក៏មិនអនុញ្ញាតឲ្យចូលរួមដែរ ។ ទីបំផុត បេតសេបា ឬ "ប្រពន្ធរបស់អ៊ូរី" មិនគួរឲ្យក្លាយជាមហេសីព្រះបាទដាវីឌបានឡើយ ។ ព្រះជាម្ចាស់ប្រព្រឹត្តិជាមួយរាស្ត្រអ៊ីស្រាអែល និងជាមួយមនុស្សជាតិទាំងអស់ គឺដោយព្រោះតែព្រះគុណាប៉ុណ្ណោះ ។*

ឲ្យគិតពីតួអង្គ និង ការរីកចំរើននៃជំនឿរបស់នាងរស់ ដែលមាននៅក្នុងកណ្ឌគម្ពីរនេះទាំងមូល ។ ខ្លឹមសារដទៃទៀតនៃរឿងនេះ ដែលប្រហែលជាមានប្រយោជន៍ក្នុងការតាមដាននោះគឺ៖

- ការសិក្សាពីចរិតលក្ខណៈនៃតួអង្គ ណាអូមី ទោះបីជារស់នៅក្នុងទឹកដីបរទេស(ប្រទេសក្រៅ) អស់រយៈពេលមួយទសវត្សរ៍ឬឈ និងនៅក្នុងពេលចុងបញ្ចប់និយាយបញ្ចេញកំហឹងចំពោះវាសនា ដែលព្រះយ៉ាវេបានដាក់កំរិតឲ្យរូបគាត់ ទោះជាយ៉ាងណាក៏ដោយ គាត់មានបុគ្គលិកលក្ខណៈដែលគួរឲ្យចាប់ចិត្តជិតអារម្មណ៍ បង្ខំឲ្យនាងរស់ចាកចោលផ្ទះសម្បែងចោលក្តីសង្ឃឹម និង ព្រះរបស់ខ្លួនមកព្រមតាម ណាអូមី ទៅកាន់ស្រុកយូដា ។
- រំពឹងគិតពីអធិបតេយ្យភាពនៃព្រះជាម្ចាស់ ដែលធ្វើការពីក្រោយឆាក ដើម្បីឲ្យនាងរស់ "ពើបប្រទះ" ដោយជ្រើសរើសទៅរើសកួរស្រូវ នៅក្នុងស្រែបូអូស ដែលបណ្តាលឲ្យ បូអូសភ្ញាក់ឡើងចំពេលដ៏ត្រឹមត្រូវនេះ ហើយដឹងប្រាកដ ថាសាច់ញាតិជិតដិតម្នាក់ទៀត នឹងដើរកាត់ទ្វារក្រុង នៅពេលព្រឹកឡើង ហើយដឹងទៀតថាអាចឲ្យនាងរស់បានកូនប្រុសជាដើម ។ ស្រដៀងគ្នានេះដែរ អាចធ្វើឲ្យយើងគិតដល់កណ្ឌគម្ពីរ អេសធើរ ដែលនៅក្នុងនោះព្រះនាម របស់ព្រះជាម្ចាស់មិនបានលើកមកនិយាយឡើយ តែការងាររបស់ព្រះអង្គ មាននៅក្នុងព្រឹត្តិការណ៍ក្នុងសាច់រឿងនោះយ៉ាងច្បាស់ ។
- ការសិក្សានៃការអធិស្ឋាន "ដែលមិនសមរម្យ" ឬ ការថ្លែងពាក្យសំដីមិនល្អប្រឆាំងទាស់នឹងព្រះជាម្ចាស់ (យ៉ាវេ) នៅក្នុងព្រះគម្ពីររបស់ពួកអ្នកជឿ របស់ព្រះអង្គ គឺគិតបញ្ចូលទាំង ណាអូមី យ៉ូប អាសាភ យេរេមា ។ល។
- ការសិក្សាពីញាតិសន្តាន ដែលអាចលោះបាន ដែល (១) ត្រូវតែជាសាច់ញាតិដែលជិតដិតជាងគេ (២) ត្រូវតែអាចជួយលោះបាន និង (៣) ត្រូវតែមានបំណងចង់លោះ ។ ភាពស្របគ្នានេះអាចធ្វើឲ្យយើងគិតដល់ព្រះយេស៊ូដែលជាតួអង្គដ៏សំខាន់ក្នុងការសម្រេចនូវការប្រោសលោះ ស្របតាមព្រះគម្ពីរសញ្ញាចាស់ ដែលទី (១) បានយកនិស្ស័យជាមនុស្ស ដែលក្លាយជា "សាច់ញាតិយ៉ាងជិតស្និតរបស់យើង" (ហេព្រើ ២:១៤-១៨; ៤:១៤-១៦) ទី (២) គឺអាចជួយប្រោសលោះបាន (ហេព្រើ ៧:២៥) ហើយនិងទី (៣) មាន

បំណាច់នឹងជួយប្រោសលោះ (យ៉ូហាន ១០:១៧-១៨; លូកា ២២:៤១-៤២)។ ពាក្យនេះបានលេចឡើង ២៣ ដងនៅក្នុងកណ្ឌគម្ពីរនាងរស់ ។[២០]

- កណ្ឌគម្ពីរនាងរស់ផ្ដល់ឲ្យនូវគំនិតនៃសន្ធិសញ្ញាដ៏ស្មោះស្ម័គ្រ ឬ សេចក្ដីស្រឡាញ់ដ៏ស្មោះស្ម័គ្រ (១:៨; ២:២០; ៣:១០) ។
- តួនាទី ដែលនាងរស់ព្រមចុះចូលជាមួយនឹងម្ដាយក្មេករបស់នាង និងស្មោះស្ម័គ្រស្ដាប់បង្គាប់តាមនោះ ឃើញមានការល្អកើតឡើងចំពោះនាង ។

សូមព្រះអង្គប្រទានពរ មកឲ្យយើងរាល់គ្នាទាំងប្រុសទាំងស្រី នូវចរិតលក្ខណៈ និង ជំនឿរបស់នាងរស់ នៅពេលដែលយើងសិក្សាពីជំនឿ និង ចរិតលក្ខណៈរបស់នាង សូមឲ្យយើងដើរតាមលំអាននៃជំហានរបស់នាងឲ្យបានល្អត្រឹមត្រូវ ។

---

(២០) ២:២០; ៣:៩; ៣:១២(២ ដង), ១៣(៤ ដង); ៤:១,៣,៤(៥ ដង), ៦(៥ ដង), ៧, ៨, ១៤ ។